ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ២៩
ចុះថ្ងៃទី១៩-០៣-០៤
សាលដីកាលេខ៖ ៧០
ចុះថ្ងៃទី២៩-១២-២០០៤

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម ... ប្រធាន
២- លោក ... ចៅក្រម
៣- លោក ... ចៅក្រម
៤- លោក... ចៅក្រមរបាយការណ៍
៥- លោក... ចៅក្រម

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
ឯកឧត្តម...អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០៨ (ឈ) ចុះថ្ងៃទី២១-០៣-២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ២៩ ចុះថ្ងៃទី១៩-០៣-២០០៤ របស់តុលាការកំពូល។

-ជនជាប់ចោទឈ្មោះ **ហផ** (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអង្គដែក កណ្តាល ឃុំពោធិព្រាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មុខរបរនគរបាល ទីលំនៅកុមទី១២ មណ្ឌល២ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ប្រពន្ធឈ្មោះ...មានកូន០៣នាក់ ឪពុកឈ្មោះ...ម្តាយឈ្មោះ...។ ឃុំខ្លួន នៅពន្ធនាគារព្រៃស។

-ត្រូវចោទពីបទៈមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅសង្កាត់លេខ៣ ខណ្ឌមិត្តភាពក្រុងព្រះសីហនុកាលពីថ្ងៃទី១១-០៤-៩៤បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-មានធារីលោក...

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍(ម្ចាស់បណ្តឹងសាទុក្ខ)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ធអ** ភេទប្រុសអាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅស្នាក់នៅភូមិ ស្រែអំបិល ឃុំ-ស្រុក ស្រែអំបិល ខេត្តកោះកុង។

-តាមរបាយការណ៍លេខ១៧៤ បក ស្តីពីករណីបាញ់សម្លាប់មនុស្ស ចុះថ្ងៃទី១៨-០៤-៩៤ របស់ស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ ដែលបញ្ជាក់ថា ៖ កាលពីថ្ងៃទី១១-០៤-៩៤ វេលាម៉ោង០,២៥នាទី នៅមណ្ឌល២ សង្កាត់៣ ខណ្ឌមិត្តភាពក្រុងព្រះសីហនុ មានករណីបាញ់បណ្តាលឱ្យមនុស្សត្រូវរបួសយ៉ាងធ្ងន់ធ្ងរ និងស្លាប់នៅមន្ទីរពេទ្យ ក្រោយពេលជួយសង្គ្រោះបាន២៤ម៉ោង។រឿងហេតុនេះគឺបង្កឡើងដោយឈ្មោះ **ហផ** ដែលបានសួរសម្លុតទៅលើទ័ពជើងទឹក ៤នាក់។ លុះក្រោយមកក៏មានការផ្ទុះអាវុធ ហើយត្រូវចំឈ្មោះ **ពឌ** បញ្ជូនដល់មន្ទីរពេទ្យក៏ស្លាប់ទៅ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុថា៖ ការចោទប្រកាន់លើឈ្មោះ **ហផ** ពីបទៈ ធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្ត នៅក្រុងព្រះសីហនុ កាលពីថ្ងៃទី១១-០៤-១៩៩៤ បទល្មើសដែលមានចែងតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៧ ចុះថ្ងៃទី០៤-០៧-១៩៩៤ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោស **ហផ** ភេទប្រុសអាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំបាំងមុខកំណត់១២ឆ្នាំ(ដប់ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទៈ ធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីថ្ងៃទី១១-០៤-៩៤។

២-ឱ្យឈ្មោះ **ហផ** សងសំណងនិងជំងឺចិត្ត ទៅលោក **ពអ** ជាដើមបណ្ដឹងរដ្ឋប្បវេណីជាប្រាក់ចំនួន២០,០០០,០០០៛(ម្ភៃលានរៀល) សំណើលើសពីនេះត្រូវបដិសេធចោល។ ករណីទណ្ឌិតខាងលើ គ្មានប្រាក់សងធនទណ្ឌគ្រប់គ្រាន់ទេ ត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារប្រាក់ធនទណ្ឌ។

៣-វត្ថុតាងមានម៉ូតូម៉ាក់សាន់យ៉ាន់ពណ៍បាញ់ខ្មុកមួយគ្រឿង ត្រូវប្រគល់ឱ្យជនជាប់ចោទឈ្មោះ **ហផ** វិញក្រោយពេលអនុវត្តសំណងគ្រប់ចំនួន។ បទល្មើសនិងការផ្ដន្ទាទោសខាងលើ មានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខ ដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្ដឹងទាសនិងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៦ ចុះថ្ងៃទី២៤-១០-២០០០ របស់មេធាវីលោក...ការពារជនជាប់ចោទឈ្មោះ **ហផ** តវ៉ាមិនសុខចិត្ត ពីសាលក្រមព្រហ្មទណ្ឌលេខ៥៧ ចុះថ្ងៃទី០៤-០៧-១៩៩៤ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា ការប្រឈមមុខគ្នានេះគឺជាការបាញ់តគ្នាទៅវិញទៅមក ហើយជនរងគ្រោះត្រូវគ្រាប់ចំនួន០៦គ្រាប់ ជាប់ឆ្អឹងជំនីរ ដែលផ្ទុយពីការដោះសារបស់ជនជាប់ចោទ បាញ់តែមួយគ្រាប់ប៉ុណ្ណោះ ហើយម្យ៉ាងទៀត បើពុំដូច្នេះទេ ជនជាប់ចោទមិនរត់គេចខ្លួនឡើយ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៨(យ) ចុះថ្ងៃទី២៦-០៣-២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤-១០-២០០២ របស់លោកមេធាវី...ការពារឱ្យជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥៧ ចុះថ្ងៃទី០៤-០៧-៩៤ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការដដែល ដោយគ្រាន់តែសម្រេចកែប្រែរយៈពេល នៃការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ **ហផ** ក្នុងចំណុចទី១ នៃសេចក្តីសម្រេចពី១២ (ដប់ពីរ)ឆ្នាំ មក៦ឆ្នាំវិញ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩-០៣-២០០៣ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទកំបាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦-០៣-២០០៣ កំបាំងមុខគូក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី២២-០៥-២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ០៨(ឈ) ចុះថ្ងៃទី២៦-០៣-២០០៣របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃការផ្ដន្ទាទោស។

-បានឃើញសារណាក្នុងបណ្ដឹងសាទុក្ខលេខ៣២ ចុះថ្ងៃទី១០-០៩-២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-បានឃើញសារណាតប ចុះថ្ងៃទី០៩-០៧-២០០៤ របស់ឈ្មោះ **ហផ**

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ មានពិរុទ្ធភាគ្រប់គ្រាន់លើឈ្មោះ **ហផ** ធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅក្រុងព្រះសីហនុ កាលពីថ្ងៃ១១-០៤-៩៤ ប្រាកដមែន សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៨(ឈ) ចុះថ្ងៃទី២៦-០៣-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្ដាប់ក្រឡាបញ្ជី អានសារណាបណ្ដឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ **ហផ** ឆ្លើយអះអាងនាពេលសវនាការថា រឿងហេតុទាំងអស់ខ្ញុំពុំបានដឹងអ្វីទេ ហើយការបាញ់តបតនោះ ខ្ញុំបាទបាញ់ឡើងទៅលើមួយគ្រាប់មែន។ ការចាប់ខ្លួនពីនគរបាលវិញនោះ ខ្ញុំបាទពុំបានឃើញនគរបាលក្រុងព្រះសីហនុអានសាលក្រម កំបាំងមុខឱ្យខ្ញុំស្ដាប់ឡើយហើយក៏ពុំបានប្រាប់ពីសាលក្រមកាត់ទោសខ្ញុំបាទដែរ។ ពេលចាប់ខ្លួននេះ មិនដឹងរឿងអ្វីទេ ហើយក៏ពុំឃើញមានអ្នកណាសួរនាំដែរ រូបខ្ញុំបាទឆ្ងល់ជានិច្ច លុះក្រោយមកខ្ញុំបាទបានពឹងមេធាវីតាមរយៈប្រពន្ធខ្ញុំ ទើបប្ដឹងឧទ្ធរណ៍តាមលិខិត

ប្រគល់សិទ្ធិជូនមេធាវីក្នុងការតវ៉ានោះ។ សូមតុលាការកំពូល មេត្តាកាត់ក្តីរកយុត្តិធម៌ឱ្យខ្ញុំបាទផង។

-បានស្តាប់មេធាវីលោក...ការពារឱ្យជនជាប់ចោទ ឡើងសន្និដ្ឋាន នាពេលសវនាការថា៖រឿងហេតុកាត់ក្តីថ្ងៃនេះ តុលាការកំពូល ជំនុំជម្រះតែលើបណ្តឹងសាទុក្ខ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដូច្នេះខ្ញុំបាទសូមទាញហេតុផលបន្តិចពីការប្រព្រឹត្តបាញ់តបតគ្នានេះ។ ដំបូងក្នុងចំណោមផឹកស៊ី មានគ្នាឯងម្នាក់ទៅទិញគ្រឿងក្លែមបន្ថែម ជួបប្រទះ ក្រុមយោធាប្រដាប់អាវុធដោយស្រែកគំរាមរករឿង ក៏បាញ់ប្រាវ ឯអ្នកទិញសាច់ក្លែមរត់មកប្រាប់ ក៏នាំគ្នារត់ផ្លោះរបងគេចពីការបាញ់នោះ ចំណែកឈ្មោះ **ហាផ** ជាកូនក្តីខ្ញុំនេះបានបាញ់ឡើងលើមួយគ្រាប់ជាការតបតប៉ុណ្ណោះ មិនអាចសន្និដ្ឋានថា កូនក្តីខ្ញុំបាញ់នេះត្រូវជនណាឡើយ។ ឯការផ្ទេរសិទ្ធិរបស់កូនក្តីពឹងមេធាវីគឺរូបខ្ញុំបាទមានសុពលភាពលើការប្តឹងឧទ្ធរណ៍ ដោយមានការភាន់ច្រឡំប៉ុណ្ណោះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាបដិសេធបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍វិញ។

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូល បានលើកឡើងបន្ថែមនាពេលសវនាការថា៖ ចំពោះសិទ្ធិរបស់មេធាវីអាចប្តឹងឧទ្ធរណ៍បានក្នុងរឿងនេះ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេច ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណា របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី២២-០៥-២០០៣ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា តាមសារណាក្នុងបណ្តឹងសាទុក្ខ ចុះថ្ងៃទី១០-០៩-២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ លើកឡើងថាសាលក្រមលេខ ៥៧ ចុះថ្ងៃទី០៤-០៧-៩៤ របស់តុលាការក្រុងព្រះសីហនុបានចូលជាស្ថាពរហើយ ចាប់ពីថ្ងៃដែលសមត្ថកិច្ចនគរបាលចាប់ខ្លួនឈ្មោះ **ហាផ** កាលពីថ្ងៃ១១-០៥-៩៩ គឺពេលនោះឈ្មោះ **ហាផ** បានដឹងពីសេចក្តីសម្រេចរបស់សាលក្រមរួចទៅហើយ ប៉ុន្តែមេធាវីរបស់ឈ្មោះ **ហាផ** ទើបប្តឹងឧទ្ធរណ៍ នៅថ្ងៃទី២៤-១០-២០០២ ឃើញថាហួសកំណត់ពេលប្តឹងឧទ្ធរណ៍០៣ឆ្នាំ ហើយពុំអាចប្តឹងឧទ្ធរណ៍បានទៀតទេ ការអះអាងដូចនេះគឺពុំមានមូលដ្ឋានច្បាស់លាស់ទេពីព្រោះថា៖

-បណ្តឹងឧទ្ធរណ៍ពុំមែនប្តឹងនៅថ្ងៃទី២៤-១០-២០០២ ទេគឺប្តឹងនៅថ្ងៃទី ១៥-០៨-២០០០តាមបណ្តឹងឧទ្ធរណ៍លេខ២៦ចុះថ្ងៃទី២៤-១០-២០០០។

-តុលាការក្រុងព្រះសីហនុ ពុំបានជូនដំណឹងពីសាលក្រមកំបាំងមុខទេនោះថា៖ ក្រោយពេលជំនុំជម្រះ ឬ ក៏ក្រោយពេលចាប់ខ្លួនក៏ដោយ។

-នៅពេលចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ ពុំបានធ្វើកំណត់ហេតុស្តីពីការចាប់ខ្លួនទេ ហើយក៏ពុំមានភស្តុតាងណាថា មុនពេលប្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៥-០៨-២០០០ ជនជាប់ចោទបានទទួលដឹងពីសាលក្រមកំបាំងមុខលេខ៥៧ ចុះថ្ងៃទី០៤-០៧-៩៤ ឡើយពីព្រោះជនជាប់ចោទបានឆ្លើយថាពេលចាប់ខ្លួន នគរបាល

ប្រាប់ខ្លួនតែពីដីកាចាប់ខ្លួន ដែលដីកានេះព្រះរាជអាជ្ញាជូនចេញមុនសាលក្រមកំបាំងមុខទៅទៀត។ ដូច្នេះក្នុងករណីនេះ តុលាការគប្បីពិចារណា ឱ្យផលប្រយោជន៍ទៅជនជាប់ចោទ ដោយទទួលស្គាល់បណ្តឹងឧទ្ធរណ៍ របស់មេធាវីដើមចោទ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៨(ឈ) ចុះថ្ងៃទី២៦-០៣-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

វិនិច្ឆ័យ សេចក្តីចំពោះមុខជនជាប់ចោទ

១-ទទួលបណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី២២-០៥-២០០៣ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៨(ឈ) ចុះថ្ងៃទី២៦-០៣-២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៩-១២-២០០៤ ។